Nº 1

# ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

**សំណួរៈ** **តើការកំណត់ទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងឃុំ សង្កាត់ នីមួយៗ ត្រូវធ្វើឡើងដោយរបៀបណា ?**

**ចម្លើយៈ** ក្នុងជំហានដំបូង គ.ជ.ប ត្រូវកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មួយ ឬ ច្រើនក្នុងឃុំ សង្កាត់នីមួយៗ នៅក្នុងរយៈពេលយ៉ាងតិច ១៥ថ្ងៃ មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ បន្ទាប់ពីបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ចំនួន និងទីតាំងការិយាល័យបោះឆ្នោតអាចធ្វើការកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប។ ការកែសម្រួលនេះត្រូវធ្វើឱ្យហើយរួចរាល់ មុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ។ ( ប.ន.៥.២)

**សំណួរៈ** **សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ នេះ តើការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវផ្អែកទៅលើអ្វីជាមូលដ្ឋាន ?**

**ចម្លើយៈ** សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ នេះ ការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវផ្អែកជាមូលដ្ឋានលើចំនួន និងទីតាំងការិយាល័យបោះឆ្នោត ដែលបានប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ ។ ( ប.ន.៥.២.១ )

**សំណួរៈ** **ចំនួន និងទីតាំងការិយាល័យបោះឆ្នោត ដែលបានប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ តើ គ.ជ.ប អាចធ្វើការកែសម្រួល ឬក៏បង្កើតការិយាល័យបោះឆ្នោតថ្មីបានដែរ ឬទេ ?**

**ចម្លើយៈ** -គ.ជ.ប អាចធ្វើការកែសម្រួលចំនួន និងទីតាំងការិយាល័យបោះឆ្នោត និងតំបន់ស្ថិតក្នុងដែនសមត្ថកិច្ច ដែលការិយាល័យនោះទទួលខុសត្រូវ ឬ /និង បង្កើតការិយាល័យបោះឆ្នោតថ្មីបន្ថែមបាន ក្នុងករណីមានការប្រែប្រួលខាងប្រជាសាស្ត្រ ឬ /និង សង្គម ឬ /និង ភូមិសាស្ត្រ ឬ /និង រដ្ឋបាល ។ ( ប.ន.៥.២.២ )

-ការកំណត់និងការកែសម្រួលចំនួន និងទីតាំងការិយាល័យបោះឆ្នោត ឬ /និង ការបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងឃុំ សង្កាត់ ត្រូវគោរពតាមលក្ខខណ្ឌនៃ ច.ប.ត.រ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ ( ប.ន.៥.២.៣ )

**សំណួរៈ** **ហេតុអ្វីបានជាការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោត ត្រូវធ្វើឡើងតាំងពីមុនថ្ងៃចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតយ៉ាងដូច្នេះ ?**

**ចម្លើយៈ** -បានជាការកំណត់ចំនួននិងទីតាំងការិយាល័យបោះឆ្នោត ត្រូវធ្វើឡើងតាំងពីមុនថ្ងៃចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ពីព្រោះជាដំបូងការិយាល័យទាំងនេះ ត្រូវបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ការិយាល័យបោះឆ្នោត ដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះត្រូវបានធ្វើបច្ចុប្បន្នភាព ឬ/និង ត្រូវបានចុះឈ្មោះថ្មី និងផ្ដល់សុពលភាពជាផ្លូវការចប់សព្វគ្រប់ដោយ គ.ជ.ប នឹងត្រូវប្រើការជាការិយាល័យបោះឆ្នោត នៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ការិយាល័យបោះឆ្នោត នឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។(ប.ន.៥.២,៤)

-ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបម្រើឱ្យតំបន់បោះឆ្នោតមួយដែលបានកំណត់ ។ ការិយាល័យបោះឆ្នោត និងតំបន់ស្ថិតក្នុងដែនសមត្ថកិច្ចដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវតែស្ថិតនៅក្នុងក្របខណ្ឌ ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ។(ប.ន.៥.២,៥)

-គ.ជ.ប ត្រូវធានាថា ការិយាល័យបោះឆ្នោតនីមួយៗ មិនត្រូវស្ថិតនៅឆ្ងាយជាង ៥គីឡូម៉ែត្រពីកន្លែងរស់នៅរបស់អ្នកបោះឆ្នោតឡើយ ។(ប.ន.៥.២,៦)

-ទីតាំងការិយាល័យបោះឆ្នោតត្រូវតែជាទីកន្លែង ដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ ។(ប.ន.៥.២,៧)

**សំណួរៈ** **ប្រសិនបើនៅក្នុងតំបន់ណាមួយដែលមានស្ទឹង ព្រែក ទន្លេ ឬជាភូមិសាស្ត្រដែលនាំឱ្យប្រជាពលរដ្ឋមានការលំបាកធ្វើដំណើរឆ្លងកាត់ តើ គ.ជ.ប ត្រូវធ្វើយ៉ាងណា ?**

**ចម្លើយៈ** ប្រសិនបើនៅកន្លែងណាមានស្ទឹង ព្រែក ទន្លេ ឬភូមិសាស្ត្រដែលធ្វើឱ្យប្រជាពលរដ្ឋមានការលំបាកធ្វើដំណើរឆ្លងកាត់ គ.ជ.ប ត្រូវតែបង្កើតការិយាល័យបោះឆ្នោតនៅសងខាងស្ទឹង ព្រែក ទន្លេទាំងនោះ ឬនៅទីតាំងជាក់លាក់ណាមួយ ដែលមានលក្ខណៈប្រសើរជាងគេ ។ (ប.ន.៥.២,៨)

-មិនត្រឹមតែនៅកន្លែងដែលមានស្ទឹង ព្រែក ទន្លេ ប៉ុណ្ណោះទេ សូម្បីតែនៅតំបន់ដាច់ស្រយាលដែលមានប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតតិចជាង ៧០០នាក់ ទោះបីជាចំនួនប្រជាពលរដ្ឋរស់នៅតំបន់នោះ មានចំនួនប៉ុន្មាននាក់ក៏ដោយ ក៏ គ.ជ.ប ត្រូវតែបង្កើតការិយាល័យបោះឆ្នោតមួយដែរ ។(ប.ន.៥.២,៩)

-គ.ជ.ប អាចបង្កើតការិយាល័យបោះឆ្នោតមួយ ឬមួយចំនួនសម្រាប់ភូមិមួយ ឬការិយាល័យបោះឆ្នោតមួយសម្រាប់ភូមិមួយចំនួន ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យសមាជិកគ្រួសារទាំងអស់ដែលមានសិទ្ធិបោះឆ្នោតក្នុងភូមិនោះ ឬទាំងនោះបានទៅបោះឆ្នោតគ្រប់ៗគ្នា ។ (ប.ន.៥.២,១០)

**សំណួរ: ក្នុងករណី ការិយាល័យមួយ មានអ្នកបោះឆ្នោតលើសពី ៧០០នាក់ តើ គ.ជ.ប ត្រូវធ្វើយ៉ាងណាទៅវិញ ?**

**ចម្លើយ:** ក្នុងពេលចុះឈ្មោះបោះឆ្នោត គ.ជ.ប ធានាថា ការិយាល័យបោះឆ្នោតមួយ ត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត យ៉ាងច្រើនបំផុតត្រឹមចំនួន ៧០០នាក់ ។ បើក្នុងករណីបញ្ជីបោះឆ្នោតណាមួយមានឈ្មោះអ្នកបោះឆ្នោតគ្រប់ចំនួន ៧០០នាក់ ហើយនោះ គ.ជ.ប ធានាថាអ្នកមកសុំចុះឈ្មោះបន្ទាប់ ត្រូវតែបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតមួយទៀត ដែលនៅក្បែរនោះក្នុងឃុំ សង្កាត់ តែមួយ ។(ប.ន.៥.២,១១)

ប៉ុន្តែក្នុងករណីការិយាល័យបោះឆ្នោតផ្សេងទៀតនៅក្បែរនោះមានចំនួនអ្នកបោះឆ្នោតពេញគ្រប់ចំនួន ៧០០នាក់ ដែរ ឬថា ពុំមានការិយាល័យបោះឆ្នោតផ្សេងទៀតក្បែរនោះដើម្បីចុះឈ្មោះជូនអ្នកមកសុំចុះឈ្មោះ ដែលនាំឱ្យការចុះឈ្មោះអ្នកបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតតែមួយមានចំនួនលើសពី ៧០០នាក់ នោះ គ.ជ.ប ត្រូវបំបែកការិយាល័យបោះឆ្នោតដែលមានឈ្មោះអ្នកបោះឆ្នោតលើសពី ៧០០នាក់ នោះ ជាការិយាល័យភ្លោះ" A " និង " B " ដោយរក្សាលេខកូដការិយាល័យដដែល និងមានទីតាំងនៅជាប់គ្នា ហើយបញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវបែកចែកជា ២ តាមចំនួនជាក់ស្តែង ។

**សំណួរ: តើ គ.ជ.ប អាចបង្កើតការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចល័តបានដែរឬទេ ?**

**ចម្លើយ:** មិនបានទេ ពីព្រោះការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត គឺជាការិយាល័យនៅនឹងមួយកន្លែង ដែលត្រូវបានបង្កើតឡើងនៅទីតាំងជាក់លាក់មួយ ក្នុងតំបន់បោះឆ្នោតមួយជាកំណត់ ហើយដែលត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។(ប.ន.៥.៣)

**សំណួរ: តើលក្ខណៈវិនិច្ឆ័យសំខាន់ ក្នុងការកំណត់ទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវស្ថិតនៅលើចំណុចអ្វី ?**

**ចម្លើយៈ** លក្ខណៈវិនិច្ឆ័យសំខាន់ក្នុងការកំណត់ទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត គឺស្ថិតនៅលើទីតាំងដែលអ្នកបោះឆ្នោតងាយរកឃើញ និងអាចធ្វើដំណើរទៅមកបានស្រួល ។ (ប.ន.៥.៤)

-ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវមានទីតាំងនៅកន្លែងណាដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ និងគ្មានការរំខាន ហើយជាការប្រសើរ ការិយាល័យនេះត្រូវស្ថិតនៅជាន់ផ្ទាល់ដី ។ (ប.ន.៥.៤.១)

**សំណួរៈ** **តើការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំនួន២ ឬច្រើនអាចតាំងនៅក្នុងអាគារតែមួយបានដែរឬទេ ?**

**ចម្លើយៈ** ក្នុងករណីចាំបាច់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំនួន២ ឬច្រើនអាចតាំងនៅក្នុងបរិវេណសំណង់ ឬអាគារតែមួយ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅ នៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោតទេ ។ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងនោះ ត្រូវតែរៀបចំខណ្ឌដាច់ពីគ្នា និងការគ្រប់គ្រងដោយឡែកពីគ្នា ។ (ប.ន ៥.៤.២ )

**សំណួរៈ** **តើទីតាំងបែបណាខ្លះដែលការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវចៀសវាងមិនត្រូវបង្កើតនោះ ?**

**ចម្លើយៈ** ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមិនត្រូវបង្កើតនៅក្នុងបរិវេណទីធ្លា និងអាគាររបស់រដ្ឋាភិបាល ដូចជា សាលាខេត្ត ក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ ជាដើម ឬនៅបន្ទាយ ឬអាគារនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ឬ/និង អាគាររបស់គណបក្សនយោបាយណាមួយឡើយ ។ (ប.ន ៥.៤.៣ )

**សំណួរៈ** **តើឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវបានគេមិនផ្សាយជាសាធារណៈជូនប្រជាពលរដ្ឋជ្រាបដែរ ឬទេ ?**

**ចម្លើយៈ** គ.ជ.ប ត្រូវបោះពុម្ពផ្សាយ និងបញ្ជូនបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទៅអាជ្ញាធររៀបចំការបោះឆ្នោត ដើម្បីចាត់ចែងបិទផ្សាយជាសាធារណៈ នៅតាមទីកន្លែង និងកាលបរិច្ឆេទ ដែលកំណត់ដោយ គ.ជ.ប ។ (ប.ន ៥.៥ )

-ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត លខ/កប ត្រូវចាត់ចែងឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យ

ចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅសាលាឃុំ សង្កាត់ និងទីកន្លែងណាមួយក្នុងឃុំ សង្កាត់ យ៉ាងតិច ១០ថ្ងៃ មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ( ប.ន ៥.៥.១ )

-ក្នុងដំណាក់កាលឃោសនាបោះឆ្នោត គខ/កប ត្រូវចាត់ចែង គឃ/សប ឱ្យបិទផ្សាយជាសាធារណៈនូវឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅទីស្នាក់ការ គឃ/សប និងនៅតាមទីកន្លែងណាមួយក្នុងឃុំ សង្កាត់ យ៉ាងតិច ១ថ្ងៃ មុនថ្ងៃចាប់ផ្តើមការឃោសនាបោះឆ្នោត ។ ( ប.ន ៥.៥.២ )

-ក្នុងដំណាក់កាលបោះឆ្នោត គខ/កប ត្រូវចាត់ចែង គឃ/សប និង គកប ត្រូវបិទផ្សាយជាសាធារណៈនូវឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅទីស្នាក់ការ គឃ/សប និង គ្រប់ទីតាំងការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ ពាក់ព័ន្ធចំនួន ១ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ( ប.ន ៥.៥.៣ )

**សំណួរ:** **តើគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត មានសិទ្ធិស្នើសុំបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានដែរ ឬទេ ?**

**ចម្លើយ:** គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត មានសិទ្ធិស្នើសុំពី គ.ជ.ប នូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃឃុំ សង្កាត់ មួយឬច្រើន បន្ទាប់ពីពេលដែលបញ្ជីនេះ ត្រូវបានកំណត់ជាផ្លូវការដោយ គ.ជ.ប ដោយត្រូវបង់ថ្លៃត្រឹមតែតម្លៃផលិត ។ ការផ្គត់ផ្គង់ចំពោះការស្នើសុំខាងលើនេះ ត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់មុន ស្មើនឹង ១០០% នៃតម្លៃផលិត ។ ( ប.ន ៥.៥.៤ )